

# ផ្ទះកក់ក្ដៅ គ្រួសារសុខសាន្ត

## វគ្គ៖ គ្រឹះស្ថានហិរញ្ញវត្ថុ ផ្លូវការ ឬស្របច្បាប់

FIRST FINANCE




Image are Generated with AI


បងដាក់ពាក្យខ្ចី ទៅខាងស្ថាប័ននេះ លក្ខខណ្ឌអនុម័តគេងាយណាស់ គេសុំមើលប្លង់ដី និងសួរថាអាចបង់បានអត់?
ដោយសារជាស្ថាប័នថ្មី ដូច្នេះបងសុំមើលឯកសារគេវិញ ។ នេះជារូបអាជ្ញាបណ្ណគេផ្ញើរមកអូនជួយមើលមើល៎


គេអនុម័ត ហើយ រង់ចាំតែបង់សេវាឲ្យគេទេ ។ តែបងមកសួរឯងសិន
ឈប់សិន! ខ្ញុំសុំឆែកមើលសិន ថាតើជាស្ថាប័នហិរញ្ញវត្ថុផ្លូវការ ឬ ក្រៅផ្លូវការ?


ពីរហ្នឹងខុសគ្នាយ៉ាងម៉េចខ្លះទៅ?
ខុសគ្នាអ្នកបង! គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការគឺត្រូវបានគ្រប់គ្រងដោយច្បាប់ ចេញអាជ្ញាប័ណ្ណដោយធនាគារជាតិ
ធ្វើម៉េចដឹង? មីអូន?!


យើងអាចផ្ទៀងផ្ទាត់ឈ្មោះគ្រឹះស្ថាននៅលើគេហទំព័រធនាគារជាតិតាមរយៈការស្កេន QR
www.nbc.gov.kh/supervision/commercial_banks.php
គ្រឹះស្ថានផ្លូវការគឺមានក្រមប្រតិបត្តិត្រឹមត្រូវអាចរកមើលលើគេហទំព័ររបស់គ្រឹះស្ថាននីមួយៗបាន
តែគ្រឹះស្ថានដែលអ្នកបងខ្ចីនេះដូចអត់មានឈ្មោះក្នុងគេហទំព័រទេ

## ចំណុចគួរចងចាំ*

ហានិភ័យផ្សេងៗ ដែលនឹងកើតមានឡើងចំពោះ អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ រួមមាន៖

- ប្រឈមនឹងការឆបោក ការកេងបន្លំ ហឹង្សា ការគំរាមកំហែង នឹងការរំលោភបំពាន ដោយសារប្រតិបត្តិការទាំងនោះ ពុំស្ថិតក្រោមច្បាប់ និងមិនមានការត្រួតពិនិត្យ ដោយនិយ័តករ ឬអាជ្ញាធរ ។ កិច្ចសន្យា និងលក្ខខណ្ឌពាក់ពន្ធ័មានលក្ខណៈបោកបញ្ឆោត មិនមានសុចរិតភាព នឹងដាក់បន្ទុកធ្ងន់ធ្ងរទៅកាន់អតិថិជន ។
- ប្រឈមនឹងការខាតបង់ហិរញ្ញវត្ថុ ដោយសារអត្រាការប្រាក់ និងកម្រៃសេវាផ្សេងៗខ្ពស់ នឹងមិនមានតម្លាភាព ។
- ប្រឈមនឹងការរឹបអូស និងលក់ឡៃឡុងលើទ្រព្យបញ្ចាំ ដោយពុំឆ្លងកាត់សេចក្ដីសម្រេចរបស់តុលាការ ។
- ប្រឈមនឹងការលិចធ្លាយព័ត៌មានបុគ្គលជាសាធារណៈ ឬតាមបណ្ដាញសង្គម ព្រមទាំងអាចក្លាយជាកម្មវត្ថុនៃការគំរាមកំហែងជាដើម ។

ជនរងគ្រោះដោយសារកម្ចីក្រៅផ្លូវការ និងខុសច្បាប់ អាចរាយការណ៍មកកាន់អគ្គស្នងការនគរបាលជាតិ តាមរយៈទូរសព្ទលេខ **023 72 68 22**

*ដកស្រង់ចេញពី កម្រងមេរៀន ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍

សូមតាមដានភាគបន្ត នៅសប្ដាហ៍ក្រោយ ▶▶

**ផ្ទះកក់ក្តៅ គ្រួសារសុខសាន្ត** ជាកម្រងរឿងខ្លីៗ ដែលនិយាយពីជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារមួយស្ថិតក្នុងជីវភាពមធ្យម ។ នៅក្នុងវគ្គនីមួយៗនៃរឿងនេះ ត្រូវបានបញ្ចូលសាររអប់រំខ្លីៗ ជូន ដល់អ្នកអាន ដើម្បីស្វែងយល់អំពីការគ្រប់គ្រង និងរៀបចំផែនការហិរញ្ញវត្ថុក្នុងគ្រួសារដំណើរការដាក់ស្នើរកម្ចីផលិតផលកម្ចី និងសាររអប់រំផ្សេងទៀតទាក់ទងនឹងការប្រើប្រាស់កម្ចីប្រកបដោយប្រសិទ្ធិភាព ។
យើងខ្ញុំស្វាគមន៍ទទួលយកគន្លឹះផ្សេងៗទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ តាមការស្នើរសុំពីប្រិយមិត្តដើម្បីបញ្ចូលទៅក្នុងសាច់រឿង ។
ដូច្នេះប្រសិនបើប្រិយមិត្តមាន គន្លឹះដែលល្អៗ អាចផ្ញើរមកកាន់ទំព័រ Facebook របស់ ហ្វឺស ហ្វាយនែន ឬតាមរយអ៊ីម៉ែល infor@firstfiance.com.kh យើងខ្ញុំនឹងត្រូវពិនិត្យហើយដាក់ជូន ប្រសិនបើយល់ឃើញថា អត្ថបទ ឬគន្លឹះនោះមានប្រយោជន៍ដល់ប្រិយមិត្តអ្នកអាន ផ្សេងទៀត ។

នាំមកជូនដោយ

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឺស ហ្វាយនែន ភីអិលស៊ី

គេហទំព័រ ហ្វឺស ហ្វាយនែន
www.firstfinance.com.kh